**កិច្ចប្រជុំទូទៅប្រចាំឆ្នាំរបស់សាលាអន្តរជាតិភ្នំពេញ**

**របាយការណ៍របស់គណៈកម្មាធិការហិរញ្ញវត្ថុ បរិក្ខារ និងធនធាន**

**ឆ្នាំសិក្សា ២០១៩ - ២០២០**

សូមគោរពឪពុកម្តាយសិស្ស បុគ្គលិកសិក្សា បុគ្គលិក និងសិស្សានុសិស្សទាំងអស់

ជាដំបូង ខ្ញុំសូមថ្លែងអំណរគុណចំពោះសមាជិកគណៈកម្មាធិការ រួមមានដូចជា Peter Herum (សមាជិកក្រុមប្រឹក្សាភិបាល និងប្រធានអនុគណៈកម្មាធិការផែនការយុទ្ធសាស្ត្រ FFRC), John Hustedt (សមាជិកក្រុមប្រឹក្សាភិបាល), Gareth Jones (នាយកសាលា), Bunthida Chea (CFO), Edwin Van Olst (អ្នកតំណាងបុគ្គលិកសិក្សា), Michael Hodgson (រដ្ឋបាលប្រតិបត្តិការ) និង Sopak Phan (ប្រធានផ្នែកធនធានមនុស្ស) ។ គណៈកម្មាធិការបានជួបប្រជុំជារៀងរាល់ខែហើយបានខិតខំធ្វើការដើម្បីធានាឱ្យមានការរាយកាណ៍ទាន់ពេលវេលា និងពិនិត្យឡើងវិញលើហិរញ្ញវត្ថុ បរិក្ខារ និងធនធានរបស់សាលាក្នុងបំណងដើម្បីធានាឱ្យបានថាទិដ្ឋភាពទាំងអស់មានលក្ខណៈត្រឹមត្រូវតាមគោលបំណង និងមាននិរន្តភាព។ ខ្ញុំសូមថ្លែងអំណរអគុណលោក Gareth Jones និងក្រុមកាងាររបស់លោកចំពោះការងារដែលពួកគេបានធ្វើដើម្បីកែលម្អគុណភាព និងធានាតម្លាភាពនៃព័ត៌មានដែលត្រូវបានចែករំលែក ត្រួសត្រាយផ្លូវសម្រាប់គណៈកម្មាធិការដើម្បីអនុវត្តភារកិច្ចមើលខុសត្រូវរបស់ខ្លួន។

របាយការណ៍នេះគ្របដណ្តប់លើប្រធានបទសំខាន់ៗចំនួន ៤៖ (ក) សមិទ្ធិផលសំខាន់ៗឆ្នាំ ២០១៩/២០២០ (ខ) របាយការណ៍ហិរញ្ញវត្ថុ (គ) ថវិការឆ្នាំ ២០២០/២០២១ និង (ឃ) មតិសន្និដ្ឋាន ។

## ក. សមិទ្ធិផលសំខាន់ៗសម្រាប់ឆ្នាំ ២០១៩/២០

១. យើងបានកែលម្អគុណភាពរបាយការណ៍ប្រចាំខែរបស់យើង ដោយបានដាក់បញ្ចូលស្ថានភាពការចុះឈ្មោះចូលរៀន របាយការណ៍អំពីប្រាក់ចំណេញ & ខាត ទ្រព្យបម្រុង/ថវិការបម្រុង និងបញ្ហាដទៃទៀត។

២. យើងបានបញ្ចប់ការវិភាគការចំណាយធៀបជាមួយអត្ថប្រយោជន៍ រវាងកម្ចីបច្ចុប្បន្នពីធនាគារ Maybank ជាមួយ OPIC និងបានសម្រេចចិត្តរក្សាកម្ចីជាមួយធនាគារ Maybank ក្នុងអត្រាការប្រាក់ថយចុះជាងមុនដែលបានចរចា។

៣. ទ្រព្យបម្រុងរបស់សាលានៅតែបន្តមានភាពរឹងមាំ ដោយមានថវិកាបម្រុងគ្រប់គ្រាន់ សម្រាប់ភាពឡើងចុះនៃការចុះឈ្មោះចូលរៀន និងមូលនិធិមូលធន អនុលោមតាមគោលនយោបាយរបស់សាលា។ បន្ថែមលើនេះ យើងបានបង្កើនចំណូលពីការប្រាក់បានមកពីថវិកាបម្រុងយ៉ាងប្រសើរបំផុត៖ (ក) បើក

គណនីជារូបិយវត្ថុរៀល ដែលផ្តល់ចំណូលការប្រាក់ប្រសើរជាងមុន ដើម្បីផ្តល់មូលនិធិសម្រាប់ការចំណាយប្រាក់រៀល និង (ខ) ពិនិត្យឡើងវិញ និងដាក់ប្រាក់បញ្ញើជាប្រាក់ដុល្លារ មានរយៈពេលយូរជាងមុន។

៤. យើងបានបញ្ចប់របាយការណ៍សវនកម្ម សម្រាប់ឆ្នាំសារពើភ័ណ្ឌ ២០១៨/២០១៩ ហើយរបាយការណ៍នេះអាចផ្តល់ជូនបានតាមការស្នើសុំពីសាលា។

៥. រថយន្តក្រុងថ្មី ឥឡូវនេះត្រូវបានប្រើប្រាស់ហើយ ជាហេតុ អាចជួយកែលម្អសេវាជូនដល់សិស្ស

៦. យើងបានស្នើឱ្យចាត់កញ្ចប់ថ្លៃចុះឈ្មោះចូលរៀនដែលបង់ប្រាក់តែមួយលើកសម្រាប់សិស្សថ្មី និងថ្លៃបង់ប្រាក់សិក្សា ដើម្បីញែកការផ្តល់មូលនិធិសម្រាប់កម្មវិធីអាហារូបករណ៍ និងកម្មវិធីសប្បុរសធម៌របស់សាលាអន្តជាតិភ្នំពេញ។ ចំណុចនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរួចហើយ ហើយនឹងចាប់ផ្តើមក្នុងឆ្នាំសិក្សា ២០២០/២១។

## ខ. របាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០១៩/២០ (បណ្តោះអាសន្ន)

ចំណូលត្រូវបានរំពឹងថានឹងបញ្ចប់ក្នុងអត្រា ៤,៨ ភាគរយ ប្រសើរជាងថវិកា អាស្រ័យដោយមានការចុះឈ្មោះចូលរៀនខ្ពស់ និងមានការកើនឡើងនៃចំណូលដទៃទៀត អាស្រ័យដោយមានការទទួលយកកម្មវិធីក្រោយម៉ោងសិក្សា និងសេវារថយន្តក្រុងកម្រិតខ្ពស់។ បន្ថែមលើនេះ យើងបានកត់សម្គាល់ឃើញមានចំណូលដ៏ច្រើនពីការប្រមូលអត្ថប្រយោជន៍ហិរញ្ញប្បទានសហរដ្ឋអាមេរិកសម្រាប់ឆ្នាំកន្លងមក។ ការចំណាយត្រូវបានរំពឹងថាមានចំនួន ៣ ភាគរយ ខ្ពស់ជាងថវិកា អាស្រ័យដោយមាន ការជួលមនុស្សបន្ថែម ការកែសម្រួលថវិកាបៀវត្ស ថ្លៃសេវាផ្នែកច្បាប់កើនឡើងពាក់ព័ន្ធជាមួយកម្ចី និងការរៀបចំរចនាសម្ព័ន្ធអត្តសញ្ញាណផ្នែកច្បាប់របស់សាលាឡើងវិញ និងការចំណាយលើការថែទាំ។ យើងបានព្យាករណ៍ថា មានថវិកាអតិរេកចំនួន ២,៣ លានដុល្លារ ដែលនឹងត្រូវដាក់បន្ថែមចូលទៅក្នុងធនធានរបស់សាលាដើម្បីផ្តល់មូលនិធិលើការវិនិយោគបន្ថែមសម្រាប់បរិក្ខារ និងមនុស្ស កម្ចីបង់ប្រាក់ជាមុន ឬទប់ទល់ជាមួយវិបត្តិហិរញ្ញវត្ថុជាសក្តាលនុពលបណ្តាលមកពីការរាតត្បាតជាសកលនៃមេរោគកូវីដ១៩។

| | ឆ.ស ២០១៩-២០ ១៩ សីហា-២០ កក្កដា (ថវិកា) | ឆ.ស ២០១៩-២០ ១៩ សីហា-២០ កក្កដា (ជាក់ស្តែង+ព្យាករណ៍) | វ៉ារីយ៉ង់ (ថវិកា/ ជាក់ស្តែង+ព្យាករណ៍) | % ការចូលរួមវិភាគទាន |
|---|---|---|---|---|
| I. ចំណូល | | | | |
| ថ្លៃសេវាបង្រៀន និងថ្លៃមូលធន | 17,568,962 | 18,245,708 | 103.9% | 93.4% |
| ថ្លៃចុះឈ្មោះ + បង់ប្រាក់ចូលរៀន | 507,150 | 483,826 | 95.4% | 2.5% |
| ចំណូលដទៃទៀត | 554,057 | 798,502 | 144.1% | 4.1% |
| I. សរុបចំណូល | 18,630,169 | 19,528,036 | 104.8% | 100.0% |
| | | | | |
| II. ការចំណាយ | | | | |
| ការចំណាយលើនិយោជិត | 10,648,437 | 10,822,741 | 101.6% | 62.7% |
| ការចំណាយផ្នែកប្រតិបត្តិការដទៃទៀត | 2,099,497 | 2,423,773 | 115.4% | 14.0% |
| ការចំណាយមូលធន | 382,816 | 409,204 | 106.9% | 2.4% |
| ការសងកម្ចី និងការប្រាក់ | 3,493,149 | 3,459,644 | 99.0% | 20.0% |
| ការចំណាយផ្សេងៗ/ចំណាយមិនបានគ្រោងទុក | 127,731 | 153,750 | 120.4% | 0.9% |
| II. សរុបការចំណាយ | 16,751,630 | 17,269,112 | 103.1% | 100.0% |
| | | | | |
| III. អតិរេកប្រតិបត្តិការ/(ឱនភាព) | 1,878,539 | 2,258,924 | 120.2% | |

## គ. ថវិកាឆ្នាំ ២០២០/២១

| | ឆ.ស ២០១៩-២០ ១៩ សីហា-២០ កក្កដា (ជាក់ស្តែង+ព្យាករណ៍) | ឆ.ស ២០១៩-២០ ១៩ សីហា-២០ កក្កដា (ថវិកា) | វ៉ារីយ៉ង់ (ថវិកា/ បណ្តោះអាសន្ន) | % ការចូលរួមវិភាគទាន |
|---|---|---|---|---|
| I. ចំណូល | | | | |
| ថ្លៃសេវាបង្រៀន + ថ្លៃមូលធន | 18,245,708 | 18,267,134 | 100.1% | 95.4% |
| ការចុះឈ្មោះ + បង់ប្រាក់ចូលរៀន | 483,826 | 330,045 | 68.2% | 1.7% |
| ចំណូលដទៃទៀត | 798,502 | 554,057 | 69.4% | 2.9% |
| I. សរុបចំណូល | 19,528,036 | 19,151,236 | 98.1% | 100.0% |
| | | | | |
| II. ការចំណាយ | | | | |
| ការចំណាយលើនិយោជិត | 10,822,741 | 11,717,548 | 108.3% | 61.3% |
| ការចំណាយផ្នែកប្រតិបត្តិការដទៃទៀត | 2,423,773 | 2,940,619 | 121.3% | 15.4% |
| ការចំណាយមូលធន | 409,204 | 1,000,000 | 244.4% | 5.2% |
| ការសងកម្ចី និងការប្រាក់ | 3,459,644 | 3,231,029 | 93.4% | 16.9% |
| ការចំណាយផ្សេងៗ/មិនបានគ្រោងទុក | 153,750 | 214,809 | 139.7% | 1.1% |
| II. សរុបការចំណាយ | 17,269,112 | 19,104,005 | 110.6% | 100.0% |
| | | | | |
| III. អតិរេកប្រតិបត្តិការ/(ឱនភាព) | 2,258,924 | 47,231 | 2.1% | |

- កាលពីថ្ងៃទី ១ ខែមេសាឆ្នាំ ២០២០ កន្លងមក ក្រុមប្រឹក្សាភិបាលបាន អនុម័តជាឯកច្ឆន្ទលើអនុសាសន៍របស់ FFRC ដើម្បីរក្សាថ្លៃបង់សាលាឱ្យនៅដដែលតាមកម្រិតបច្ចុប្បន្ន។ សូមកត់សម្គាល់ផងដែរថា សាលាអន្តរជាតិភ្នំពេញ បានឈានជិតដល់ការបំពេញមុខងារពេញសមត្ថភាព ហើយយើងព្យាករណ៍ថាចំណូលនឹងត្រូវថយចុះបន្តិច
- ស្របពេលជាមួយគ្នានេះដែរ ការចំណាយនឹងត្រូវកើន ១០% ភាគច្រើនគឺអាស្រ័យត្រូវចំណាយសម្រាប់មនុស្សក្នុងចំនួនបន្ថែម ការបង់ប្រាក់អតីតភាពការងារ និងការបង់ប្រាក់បញ្ចប់កិច្ចសន្យាការងារ តាមប្រកាស ការផ្លាស់ប្តូរលើអត្ថប្រយោជន៍របស់និយោជិត និងការកែលម្អ និងថែទាំបរិក្ខារសាលារៀន។
- អតិរេកតិច ក្នុងទឹកប្រាក់ ៤៧ ពាន់ ដុល្លារអាមេរិក។

ថវិកាបម្រុង

- មានថវិកាបម្រុងការចុះឈ្មោះចូលរៀនក្នុងទឹកប្រាក់ ៤ លានដុល្លា និងថវិកាបម្រុងមូលធនក្នុងទឹកប្រាក់ ៤. ១ លានដុល្លា អនុលោមតាមគោលនយោបាយ

## ឃ. មតិសន្និដ្ឋាន

ស្ថានភាពហិរញ្ញវត្ថុរបស់សាលាអន្តរជាតិភ្នំពេញ មានភាពរឹងមាំ។ ដោយមានថវិកាបម្រុងគ្រប់គ្រាន់ សាលាស្ថិតក្នុងគោលជំហរដ៏ល្អអាចជំនះលើភាពតានតឹងជាសក្តានុពល ដែលអាចកើតមាននៅពេលអនាគត។

ក្នុងឆ្នាំសិក្សាខាងមុខនេះ ក្រៅពីអនុវត្តភារកិច្ចក្នុងការមើលការខុសត្រូវរបស់ខ្លួន FFRC នឹងផ្តោតការយកចិត្តទុកដាក់លើការគាំទ្រសាលាអន្តរជាតិភ្នំពេញក្នុងការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ (២០២០-២០២៤)។ ដោយឡែកសម្រាប់ FFRC ការផ្តួចផ្តើមគំនិតក្រោមផែនការនេះ រួមមានដូចជា ការកែលម្អព័ត៌មានផ្នែកការគ្រប់គ្រង ដើម្បីលើកកម្ពស់ការសម្រេចចិត្តទាន់ពេលវេលា និងការធ្វើសកម្មភាពទាន់ពេលវេលា។ គណៈកម្មាធិការ នឹងផ្តោតការយកចិត្តទុកដាក់ជាអាទិភាពលើការពង្រឹងគោលនយោបាយ និងនីតិវិធីរបស់សាលាក្នុងការកែលម្អការធ្វើកញ្ចប់ថវិកា ការគ្រប់គ្រងទ្រព្យសកម្ម រួមទាំងផែនការលទ្ធកម្ម និងការថែទាំ និងការគ្រប់គ្រងទ្រព្យបម្រុងទុកផងដែរ។ នៅក្នុងផ្នែកធនធានមនុស្ស យើងនឹងពិនិត្យឡើងវិញលើបៀវត្ស និងអត្ថប្រយោជន៍ ព្រមទាំងពង្រឹងការគ្រប់គ្រងលទ្ធផលការអនុវត្តការងាររបស់យើង និងកម្មវិធីអភិវឌ្ឍបុគ្គលិក ទាំងសម្រាប់បុគ្គលិកសិក្សា និងបុគ្គលិក ដើម្បីធានាឱ្យបានថា យើងអាចរក្សាបានមនុស្សប្រកបដោយសក្តានុពលខ្ពស់ និងផ្តល់រង្វាន់ដល់លទ្ធផលការងារប្រសើរ។ ថ្វីបើយើងសង្ឃឹមថា ជំងឺកូវីដ ១៩ នឹងមិនមានផលប៉ះពាល់ធំដុំ មកលើប្រតិបត្តិការរបស់សាលាអន្តរជាតិភ្នំពេញ និងសហគមន៍ដែលសាលាបម្រើឱ្យក្តី ប៉ុន្តែ FFRC បានត្រៀមខ្លួន និងប្តេជ្ញាចិត្តដើម្បីធានាឱ្យបានថា ហិរញ្ញវត្ថុ បរិក្ខារ និងធនធានរបស់សាលាអន្តរជាតិភ្នំពេញ នឹងបន្តប្រកបដោយគុណភាព ជាអត្ថប្រយោជន៍ សម្រាប់សាលាអន្តរជាតិនាំមុខគេក្នុងក្រុងភ្នំពេញ។

សូមទទួលការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ

Mimi Concha

សមាជិកក្រុមប្រឹក្សាភិបាល និងប្រធាន FFRC